ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

លេខ.....៣៧.........អ.ន.ក

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣ វិទ្យុអាស៊ីសេរី បានផ្សព្វផ្សាយព័ត៌មានថា "កសិករនៅ ខេត្តកណ្តាល អស់សង្ឃឹមក្នុងការដាំដុះក្រោយភ្ជួរបន្លែចោលដោយសារគ្មានទីផ្សារ"។

អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា ការចុះផ្សាយព័ត៌មានរបស់វិទ្យុអាស៊ីសេរី គ្មានភាពច្បាស់លាស់ឱ្យអគ្គនាយកដ្ឋានកសិកម្មអាច ពិនិត្យដោះស្រាយបញ្ហាដូចដែលបានលើកឡើងនេះឡើយ។ ជាក់ស្តែង ការលើកឡើងថា លោក **សំ សុគីន** បានភ្ជួរបន្លែសាលាដចោលចំនួន ៥គោននោះ គឺមិនពិតទេ ដោយសារការចុះស្រាវជ្រាវមិនបានរកឃើញថា ឈ្មោះ លោក **សំ សុគីន** បានឈូសសាលាដចោលទេ តែលេចចេញកសិករឈ្មោះ **ហេង** នៅស្រុកកោះធំ ធ្លាប់បានឈូសចោលដំណាំសាលាដ ដែលមានអាយុកាលចាស់សល់ពីការប្រមូលផលនិងដាំចម្រុះជាមួយ ដំណាំត្រប់ ដើម្បីធ្វើការដាំដុះឡើងវិញ។ ម្យ៉ាងទៀត ការចុះផ្សាយព័ត៌មានថា តម្លៃត្រសក់ចុះថោកនិងដាក់ រូបភាពបុរសដេកលើត្រសក់ គឺជារូបភាពចាស់ដែលបានកើតឡើងតាំងពីឆ្នាំ២០១៩មកម្លេះ នៅពេលប្រទេស កម្ពុជាយើង ក៏ដូចជាពិភពលោកបានទទួលរងវិបត្តិជំងឺកូវីដ១៩។

ជារួម រាល់ការលើកឡើងរបស់វិទ្យុអាស៊ីសេរីខាងលើ មិនបានឆ្លុះបញ្ចាំងបច្ចុប្បន្នភាពរបស់ប្រជា កសិករដែលកំពុងដាំដុះដំណាំបន្លែនៅខេត្តកណ្តាលនោះទេ។ ការលើកឡើងដោយអ្នកកាសែតក្រោមឈ្មោះ ក្លែងក្លាយថា **ជាតិ ចំណាន** អាចជាចេតនាបំភ្លៃការពិត ដោយប្រើប្រាស់រូបភាពសកម្មភាពចាស់ឆ្នាំ២០១៩ និងលើកឡើងអំពីការភ្ជួរចោលបន្លែចាស់ៗដើម្បីធ្វើការដាំដុះឡើងវិញ។

សូមជម្រាបថា កសិករខ្មែរដែលខិតខំតស៊ូព្យាយាម បានដឹងច្បាស់ពីហានិភ័យទីផ្សារនិងអាកាសធាតុ ជាពិសេសកសិករដែលនៅតែឈរជើងជាង១០ឆ្នាំដូចដែលឈ្មោះ **ជាតិ ចំណាន** បានលើកដូច្នេះ តើកសិករ រូបនេះបានខាតនិងឈូសបន្លែចោលរហូតឬ? បើខាត១០ឆ្នាំហើយ តើគាត់នៅតែដាំដុះទៀតបានដែរឬទេ? អ្នកកាសែត **ជាតិ ចំណាន** នេះមិនបានស្រាវជ្រាវអំពីផលចំណេញមធ្យមប្រចាំឆ្នាំរបស់កសិករដាំបន្លែនោះឡើយ។

តាមការសាកសួរតម្លៃបន្លែបោះដុំនៅផ្សារតាខ្មៅនិងផ្សារក្ដូរស្រូវនៅរាជធានីភ្នំពេញ របស់អគ្គនាយដ្ឋាន កសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣ បានឱ្យ ដឹងថា សាលាដមានតម្លៃ៧០០-៨០០៛/គ.ក្រ ត្រសក់មានតម្លៃ ៨០០-១ ២០០៛/គ.ក្រ. ខាត់ណាដើមមាន តម្លៃ ១ ០០០-១ ២០០៛/គ.ក្រ និងម្ទេសដៃនាងមានតម្លៃ ៦ ០០០៛/គ.ក្រ។

អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427

អគ្គនាយកដ្ឋានកសិកម្ម សូមជម្រាបជូនកសិករ និងសាធារណជនឱ្យបានជ្រាបថា កសិករមានជម្រើសប្រឡូកនឹងទីផ្សារសេរីដោយខ្លួនឯងដោយដាំដុះដំណាំដែលខ្លួនវាយតម្លៃថាត្រូវនឹងទីផ្សារ ឬមានជម្រើសធ្វើកសិកម្មតាមកិច្ចសន្យា។ ក្នុងករណីទី២ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំង ២៥ នឹងជួយធ្វើសាក្សីលើកិច្ចសន្យាកសិកម្មនេះដើម្បីធានាជូនបងប្អូនកសិករថា អ្នកទិញនឹងធានាទីផ្សារជូនតាមពេលវេលាដែលបានកំណត់។ ប៉ុន្តែកសិករក៏ត្រូវមានកាតព្វកិច្ចលក់ក្នុងថ្លៃដែលបានសន្យាដូចគ្នា។ នេះជាវិធីសាស្រ្តធានាទីផ្សារកសិផលមុនពេលធ្វើការដាំដុះ។

អគ្គនាយកដ្ឋានកសិកម្មសង្ឃឹមថា សាធារណជននឹងបានយល់ច្បាស់អំពីការពិតនៃការងារកសិកម្ម ហើយអ្នកកាសែតឈ្មោះក្លែងក្លាយរបស់អាស៊ីសេរី **ជាតិ ចំណាន** ក៏អាចយល់បន្ថែមផងដែរ។

ថ្ងៃអាទិត្យ ៥កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣